# ទំនុកដំកើង ១២៩-១៣១ ក្រុមទីបួនដែលមានបីទំនុកដំកើង
# (សូមមើលសេចក្តីណែនាំសំរាប់ទំនុកដំកើង ១២០-១៣៤)

អ្នកនិពន្ធ រ៉ូហ្វ លេភិឡារ

ក្រុមទីបួនដែលមានទំនុកដំកើងបីមិនដូចបីក្រុមដំបូងដែលការសំដៅទៅលើស៊ីយ៉ូនមានតែក្នុងទំនុកដំកើងទីមួយនៅក្នុងក្រុមនេះ (១២៩:៥) ប៉ុណ្ណោះ។ ក្រុមនេះដូចក្រុមទីបីដែលវាគឺជាការធ្វើធម្មយាត្រានៃចិត្ត។ ទំនុកដំកើង ១២៩ និង១៣០ និយាយអំពីការគំរៀមកំហែងផ្ទាល់និងពីខាងក្នុង ទំនុកដំកើង ១២៩ អំពីការថប់បារម្ភ ហើយទំនុកដំកើង ១៣០ អំពីអំពើបាប។ នៅក្នុងទំនុកដំកើង ១២៩ ព្រះអម្ចាស់បានសង្គ្រោះអ៊ីស្រាអែល (ខ. ១-៤) ហើយទ្រង់នឹងវិនិច្ឆ័យពួកខ្មាំងសត្រូវដែលមិនគោរពព្រះអម្ចាស់ (ខ. ៥-៨)។ ទោះយ៉ាងណា សេចក្តីសុច្ចរឹតរបស់ព្រះអាចនាំទៅដល់ការវិនិច្ឆ័យសំរាប់អ៊ីស្រាអែលផងដែរ (១៣០) ពីព្រោះគ្មានអំពើបាបណាអាចឈរនៅចំពោះទ្រង់បានឡើយ (១៣០:៣)។ ប៉ុន្តែទ្រង់គឺជាព្រះដែលអត់ទោស (១៣០:៤) ស្រលាញ់និងប្រោសលោះយើង (១៣០:៧)។ ដូច្នេះ ទំនុកដំកើង ១៣១ ប្រកាសថាមានសេចក្តីសំរាកនៅក្នុងចិត្តនិងសេចក្តីសង្ឃឹមនៅក្នុងព្រះអម្ចាស់។

**ទំនុកដំកើង ១២៩**

ទំនុកដំកើងនេះអាចមានកាលបរិច្ឆេទចាប់ពីចំនុចស្ទើរតែទាំងអស់នៅក្នុងប្រវត្តិសាស្ត្ររបស់អ៊ីស្រាអែលដែលពោរពេញទៅដោយការទុក្ខលំបាក។ តែជាតិសាសន៍ភាគច្រើនមានទំនោរ ត្រឡប់ទៅមើលអ្វីដែលពួកគេបានសំរេចបាន នៅទីនេះអ៊ីស្រាអែលឆ្លុះបញ្ចាំងលើអ្វីដែលពួកគេបាននៅសេសសល់។ មេរៀនពីប្រវត្តិសាស្ត្រគឺច្បាស់លាស់គឺ ពួកអ្នកកៀបសង្កត់គេចុងក្រោយនឹងបរាជ័យ (ខ. ២) ពីព្រោះព្រះអម្ចាស់គឺសុច្ចរឹត (ខ. ៤)។ ពួកខ្មាំងសត្រូវនាំមកនូវចំណង ប៉ុន្តែព្រះអម្ចាស់ប្រទានសេរីភាព (ខ. ៤)។ មានឧទាហរណ៍ជាច្រើននៅក្នុងព្រះគម្ពីរសញ្ញាចាស់ដែលព្រះបានសង្គ្រោះអ៊ីស្រាអែលពីពួកខ្មាំងសត្រូវរបស់ពួកគេ។ ដូច្នេះ ពួកអ្នកច្រៀងទទួលបានសេចក្តីក្លាហានពីការនឹកចាំអតីតកាលហើយប្រឈមនឹងព្រះដោយការដឹងគុណហើយប្រឈមនឹងពួកខ្មាំងសត្រូវដោយការជំនះ។

**ខ. ១-៤** ខពីរដំបូងមានរចនាសម្ព័ន្ធអំពីមនុស្សម្នាក់កំពុងធ្វើការប្រកាសមួយហើយបន្ទាប់មកអញ្ជើញអ៊ីស្រាអែលឲ្យចូលរួមនិយាយប្រកាសឡើងវិញ។ ការប្រកាសនៅទីនេះគឺ «តាំងពីខ្ញុំនៅក្មេងគេបានធ្វើទុក្ខខ្ញុំជាច្រើនដងហើយ»។ សំរាប់ទំនុកដំកើងផ្សេងៗទៀតដែលចាប់ផ្តើមដោយរចនាសម្ព័ន្ធដូចគ្នា សូមមើល១១៨:១-២ និង១២៤:១-១។ ការលើកឡើងអំពីយុវភាពរបស់អ៊ីស្រាអែលធ្វើឲ្យយើងគិតអំពីការរំដោះចេញពីការគ្រប់គ្រងរបស់ស្រុកអេស៊ីព្ទ (ឧទាហរណ៍: ហូសេ ១១:១) ជាព្រឹត្តិការណ៍ដែលបានរំលឹកអំពីពិធីបុណ្យពីរក្នុងចំណោមពិធីបុណ្យបីរបស់អ្នកធ្វើដំណើរទៅថ្វាយបង្គំព្រះ។ (សូមចងចាំថាទំនុកដំកើងទាំងនេះភាគច្រើនត្រូវបានគេច្រៀងពេលកំពុងឡើងទៅយេរូសាឡឹមសំរាប់ពិធីបុណ្យរបស់អ្នកធម្មយាត្រា)។

ពាក្យប្រៀបធៀបពីរដំណាក់ដែលបង្ហាញថាអ៊ីស្រាអែលជាមនុស្សម្នាក់ដែលគេធ្វើឲ្យមានទោស ហើយស្នាមវាយនៅលើខ្នងរបស់គាត់ជា*គន្លង*របស់វាលភ្ជួរ (ខ. ៣) គឺជារូបភាពសំខាន់ដែលរំលឹកយើងអំពីការកៀបសង្កត់ដូចជារូបភាពខ្លះពីសម័យខ្មែរក្រហមដែរ។ សេចក្តីពិតដែលថាអ៊ីស្រាអែលនៅមានជីវិតផ្តល់ភស្តុតាងថា ព្រះបានការពារពួកគេ។ នៅក្នុងទំនុកដំកើងនេះ ពួកគេមិនរអ៊ូរទាំទៅកាន់ព្រះដោយសារតែបទពិសោធន៍ជូរចត់របស់ពួកគេនោះទេ ប៉ុន្តែពួកគេទទួលស្គាល់ថាព្រះយ៉ាវេសុច្ចរឹតហើយព្រះអង្គសំដែងសេចក្តីសុច្ចរឹតរបស់ទ្រង់នៅក្នុងការជួយសង្គ្រោះពួកគេ។ បទចំរៀងអ្នកបំរើនានានៅក្នុងកណ្ឌអេសាយផ្តល់រូបភាពស្រដៀងគ្នាមួយដើម្បីពិពណ៌នាអំពីបទពិសោធន៍របស់ព្រះមែស្ស៊ី (ឧទាហរណ៍: អេសាយ ៥០:៦, ៥៣:៥)។ ព្រះគម្ពីរសញ្ញាថ្មីហៅពួកគ្រីស្ទបរិស័ទឲ្យដើរតាមគំរូរបស់ព្រះគ្រីស្ទដែលទ្រង់ស្មោះត្រង់នៅពេលទ្រង់កំពុងត្រូវគេបៀតបៀន ហើយបង្ហាញថាពួកសាវ័ករីករាយនឹងធ្វើដូច្នោះ។

**ខ. ៥-៨** កិរិយាស័ព្ទនៅក្នុងខ. ៥-៨ អាចជាទំនាយឬជាសេចក្តីអធិស្ឋាន។ ស៊ីយ៉ូនគឺជា «ទីក្រុងរបស់ព្រះនៃយើងខ្ញុំ» (៤៨:១) «ភ្នំ....សំរាប់ទីលំនៅរបស់ទ្រង់» (៦៨:១៦) ហើយជារូបភាពនៃប្រជារាស្ត្ររបស់ព្រះ។ នៅក្នុងទំនុកដំកើង ៨៧

និយាយថាពួកសាសន៍ដទៃដែលដាក់ការទុកចិត្តរបស់ពួកគេទៅលើព្រះពិតដែលមានព្រះជន្មរស់ គឺជារបស់ស៊ីយ៉ូន ហើយពួកគេទទួលស្គាល់សេចក្តីពិតនេះ។ ដូច្នេះ ដែលស្អប់ស៊ីយ៉ូនមិនមែនគ្រាន់តែស្អប់ទីក្រុងមួយនោះទេ គឺវាតំណាងឲ្យការស្អប់ព្រះនិងប្រជារាស្ត្ររបស់ទ្រង់ ដែលជាសេចក្តីចំកួតនិងអាក្រក់បំផុត។ ដូច្នេះ វាត្រឹមត្រូវដែលថាអស់អ្នកដែលបដិសេធស៊ីយ៉ូននឹងស្វិតក្រៀមទៅ (ខ. ៦)។ *ស្មៅដែលដុះនៅលើដំបូលផ្ទះ* ដំបូលខ្ពស់បំផុតនៅលើទីលំនៅនៅក្នុងអ៊ីស្រាអែលគឺជាសំណង់មានធ្នឹមកាត់ជញ្ជាំងដែលត្បាញបញ្ចូលជាមួយត្រែងនិងស្មៅ។ បន្ទាប់មកដំបូលទាំងមូលត្រូវបានបូកដោយគុកបំពេញចន្លោះមិនឲ្យទឹកជ្រាបចូល។ គ្រាប់រុក្ខជាតិដែលនៅសល់ក្នុងស្មៅឬគុកអាចដុះពន្លកយ៉ាងលឿន ប៉ុន្តែនឹងងាប់ទៅវិញយ៉ាងលឿនដែរដោយសារតែពួកវាខ្វះឫស។ រូបភាពអំពីស្មៅស្វិតក្រៀមមិនគ្រាន់តែត្រូវបានប្រើសំរាប់ពួកខ្មាំងសត្រូវប៉ុណ្ណោះទេ ប៉ុន្តែសំរាប់មនុស្សជាតិជាទូទៅ(នៅក្នុង ទំនុកដំកើង ៩០:៥-៦..., អេសាយ ៤០:៦-៨)។ អស់អ្នកដែលស្អប់ស៊ីយ៉ូនមិននៅជាអចិន្ត្រៃ (ខ.៦) បរាជ័យ (ខ. ៧) ហើយមិនត្រូវបានរាប់បញ្ចូលទៅក្នុងសហគមន៍នៃព្រះពរនោះឡើយ (ខ. ៨ ប្រៀបធៀបៈ នាងរស់ ២:៤)។

**ការអនុវត្ត**

កណ្ឌគម្ពីរវិវរណៈលើកយកផ្ទៃរឿងរបស់ទំនុកដំកើងនេះមកបង្ហាញ។ កណ្ឌវិវរណៈព្រមានពួកគ្រីស្ទបរិស័ទថា ក្នុងលោកិយនេះនឹងបន្តមានមនុស្សជាច្រើនដែលប្រឆាំងនឹងព្រះហើយនិងរាស្ត្ររបស់ទ្រង់ ហើយនឹងមានអំណាចធ្វើឲ្យពួកគ្រីស្ទបរិស័ទមានទុក្ខលំបាក។ ជាចុងបញ្ចប់ព្រះនឹងបំផ្លាញអស់អ្នកដែលប្រឆាំងនឹងទ្រង់ ពួកគេដូចជាស្មៅនៅលើដំបូលដែលស្វិតក្រៀមទោទៅមុនវាអាចដុះឡើង (ខ. ៦)។ ទោះបីជាព្រះចង់ឲ្យមនុស្សទាំងអស់បានប្រែចិត្តនិងបានសង្រ្គោះយ៉ាងណាក៏ដោយ ទ្រង់សុច្ចរឹតហើយនឹងដាក់ទោសពួកអ្នកប្រព្រឹត្តអាក្រក់។ ដូច្នេះ យើងមានអារម្មណ៍ខុសគ្នាចំពោះការនេះ។ ម្យ៉ាង យើងចង់ឲ្យមនុស្សបានសង្រ្គោះ ប៉ុន្តែម្យ៉ាងវិញទៀត យើងរីករាយនៅក្នុងសេចក្តីសុច្ចរឹតរបស់ព្រះដែលរួមទាំងការវិនិច្ឆ័យរបស់ទ្រង់ដល់អស់អ្នកដែលស្អប់ទ្រង់និងរាស្ត្ររបស់ទ្រង់នឹងមិនត្រូវបានរាប់បញ្ចូលទៅក្នុងព្រះពររបស់ទ្រង់ឡើយ (ប្រៀបធៀបៈ វិវរណៈ ៦:៩-១១)។


## Bibliography

Carson, D.A., R. T. France, J. A. Motyer & G. J. Wenham, Ed. (1994), *New Bible commentary: 21st century edition*, (4th ed.) Leicester, England; Downers Grove, IL: Inter-Varsity Press.

Henry, M. (1994), *Matthew Henry's commentary on the whole Bible: Complete and unabridged in one volume*, Peabody: Hendrickson.

Kidner, D. (1975). *Vol. 16*: *Psalms 73–150: An Introduction and Commentary*. Tyndale Old Testament Commentaries (465–467). Nottingham, England: Inter-Varsity Press.

Matthews, V. H., M. W. Chavalas & J.H. Walton (2000), *The IVP Bible background commentary: Old Testament*, Downers Grove, IL: InterVarsity Press.

Wilcock, Michael. (2001), *The Message of Psalms 73-150.* The Bible Speaks Today Commentaries. Leicester, England: Inter-Varsity Press.